# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់នៅចំប៉ា
# ថ្ងៃទី០២ មីនា ២០១៧

អត្ថបទទី១៖ ទក ៣០,១៥-២០
ដំណឹងល្អ៖ លក ៩,២២-២៥

បងប្អូនជាទីស្រឡាញ់!

ម្សិលមិញយើងបានចូលនៅក្នុងរដូវ៤០ថ្ងៃ ជារដូវដែលព្រះសហគមន៍ឲ្យយើងកែប្រែចិត្តគំនិត ជារដូវដែលព្រះសហគមន៍ឲ្យយើងទៅរកព្រះជាម្ចាស់សារជាថ្មីនៅក្នុងជីវិតរបស់យើង។ ជារដូវដែលយើងចូលជាមួយព្រះយេស៊ូដើម្បីរៀបចំខ្លួនសោយទិវង្គត ដូចយើងបានស្តាប់នៅក្នុងអត្ថបទគម្ពីរថ្ងៃនេះ "**បុត្រមនុស្សត្រូវរងទុក្ខវេទនាយ៉ាងខ្លាំង ពួកព្រឹទ្ធាចារ្យ ពួកនាយកបូជាចារ្យ ពួកបណ្ឌិតខាងវិន័យ នឹងបោះបង់លោកចោល ថែមទាំងសម្លាប់លោកទៀតផង**"។ រដូវ៤០ថ្ងៃជារដូវដែលចូលជាមួយព្រះយេស៊ូយ៉ាងជិតស្និត រហូតដល់ព្រះយេស៊ូសោយទិវង្គត ក្រោយមកយើងទន្ទឹងរងចាំព្រះយេស៊ូមានជីវិតថ្មី។ ថ្ងៃនេះយើងបានស្តាប់សំនួរនៅក្នុងអត្ថបទទីមួយ "**មើល៍ ថ្ងៃនេះ ខ្ញុំឲ្យបងប្អូនជ្រើសរើសយកជីវិតឬសេចក្តីស្លាប់? អំពើល្អឬអំពើអាក្រក់?** ច្បាស់ហើយថាយើងជ្រើសរើសជីវិតនិងអំពើល្អ។ បើយើងពិចារណា យើងពិនិត្យមើលជីវិតរបស់យើងប៉ុន្មានដងយើងធ្វើអំពើអាក្រក់ ដែលខុសនឹងធម៌វិន័យរបស់ព្រះយេស៊ូ ធ្វើខុសនឹងសេចក្តីស្រឡាញ់ដែលព្រះយេស៊ូណែនាំឲ្យយើងធ្វើសម្រាប់អ្នកដទៃ។ ទោះបីយើងអាចជ្រើសរើសនៅមុខព្រះជាម្ចាស់ ខ្ញុំជ្រើសរើសអំពើល្អ ខ្ញុំសុំឲ្យអំពើអាក្រក់ចេញឆ្ងាយពីខ្លួនរបស់ខ្ញុំ ប៉ុន្មានដងនៅក្នុងជីវិតយើងដែលយើងបានធ្វើអំពើអាក្រក់។ នៅមុខព្រះយេស៊ូ នៅមុខឈើឆ្កាងយើងបានឆ្លើយច្បាស់ថា ខ្ញុំជ្រើសរើសអំពើល្អ ប៉ុន្តែនៅក្នុងជីវិតរបស់យើងយើងបានជ្រើសរើសអំពើអាក្រក់។ ដូច្នេះ៤០ថ្ងៃដែលយើងខាងមុខនេះ ជាឱកាសមួយដើម្បីកែប្រែចិត្តគំនិត "**ខ្ញុំបង្គាប់ឲ្យអ្នករាល់គ្នានៅថ្ងៃនេះ ឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក ហើយដើរតាមមាគ៌ារបស់ព្រះអង្គ**"។ ជាពេលវេលាដើម្បីស្តាប់បង្គាប់ព្រះជាម្ចាស់ និងស្រឡាញ់ព្រះជាម្ចាស់ បើយើងភ្លេចខ្លួនបន្តិចម្តងៗយើងដើរឆ្ងាយពីព្រះជាម្ចាស់។ យើងអរព្រះគុណព្រះសហគមន៍ដែលណែនាំឲ្យយើងមានរដូវ៤០ថ្ងៃ ដើម្បីមើលព្រះយេស៊ូសារជាថ្មី ដើម្បីប្រកាសថាពិតមែនខ្ញុំស្រឡាញ់ព្រះជាម្ចាស់ណាស់ ពិតមែនខ្ញចង់ជ្រើសរើសផ្លូវល្អណាស់?។ ព្រះជាម្ចាស់មានសំនួរថា "**ខ្ញុំឲ្យបងប្អូនជ្រើសរើសយកជីវិតឬសេចក្តីស្លាប់?**" ប៉ុន្តែយើងជ្រើសរើសជីវិតរបៀបណា? តាមរបៀបលោកីយ៍មានន័យថាយើងចង់មានជីវិតវែង១០០ឆ្នាំ មានទ្រព្យសម្បត្តិច្រើន យើងចង់មានអំណរសប្បាយពេញខ្លួន ឬយើងជ្រើសរើសជីវិតតាមរបៀបព្រះយេស៊ូ។ ថ្ងៃនេះក្នុងព្រះគម្ពីរដំណឹងល្អព្រះយេស៊ូមានរបៀបពិសេសក្នុងការជ្រើសរើសជីវិត "**អ្នកណាចង់ដើរតាមខ្ញុំត្រូវតែលីឈើឆ្កាង ហើយ**

មកតាមខ្ញុំចុះ **ត្បិតអ្នកណាចង់បានរួចជីវិតអ្នកនោះនឹងបាត់បង់ជីវិត**" អំបាញ់មិញយើងចង់បានជីវិត ប៉ុន្តែពេលនេះព្រះយេស៊ូថា អ្នកណាចង់បានជីវិតអ្នកនោះនឹងបាត់បង់ជីវិត ប៉ុន្តែអ្នកណាចង់ដើរតាមព្រះយេស៊ូយើងត្រូវតែលះបង់ចោល។ របៀបព្រះយេស៊ូជារបៀបដែលណែនាំ ឲ្យយើងបើកចិត្តគំនិតទូលំទូលាយ ដើម្បីទទួលស្វាគមន៍បងប្អូនឯទៀតៗ របៀបព្រះយេស៊ូជារបៀបដែលយើងសុខចិត្តតស៊ូ។

រដូវ៤០ថ្ងៃយើងមានបីចំនុចដ៏សំខាន់ គឺ **អធិដ្ឋាន ដាក់ទាន តមអាហារ** តែអ្វីដែលសំខាន់បំផុតគឺយើងសុខចិត្តលះបង់ចោល ដើម្បីបើកចិត្តគំនិតស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីស្រឡាញ់បងប្អូនឯទៀតៗ។ នៅមុខព្រះវិហារយើងមានហិបមួយ រៀងរាល់ថ្ងៃសុក្រដែលបងប្អូនតមអាហារដាក់លុយម្តងមួយពាន់ ពីរពាន់ បីពាន់រៀល ដើម្បីចែករំលែកជាមួយបងប្អូនឯទៀត។ តមអាហារ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែមទៀត និងដើម្បីចែករំលែកជាមួយបងប្អូនឯទៀតៗ។ ដូច្នេះថ្ងៃនេះពេលយើងជ្រើសរើសជីវិត មិនមែនតាមរបៀបមនុស្សទូទៅ ប៉ុន្តែយើងជ្រើសរើសជីវិតតាមរបៀបព្រះជាម្ចាស់ឲ្យយើងជ្រើសរើស។ ក្នុងរដូវ៤០ថ្ងៃនេះយើងជ្រើសរើសជីវិតតាមរបៀបព្រះជាម្ចាស់ អធិដ្ឋានថែមទៀត ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថែមទៀត ណែនាំឲ្យយើងស្រឡាញ់ព្រះជាម្ចាស់ឲ្យយើងធ្វើតាមព្រះជាម្ចាស់តែម្តង។ ដោយសារព្រះជាម្ចាស់ជាគំរូសម្រាប់យើង ព្រះជាម្ចាស់ជាជីវិតរបស់យើង ព្រះជាម្ចាស់ណែនាំឲ្យយើងធ្វើជាមនុស្សថ្មី។

យប់នេះដែលយើងអធិដ្ឋានសម្រាប់ការត្រាស់ហៅ ជាឱកាសមួយសម្រាប់បងប្អូនទាំងអស់នៅស្ងៀមស្ងាត់ ស្តាប់ព្រះបន្ទូល ឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចូលនៅក្នុងជីវិតថែមទៀត ដើម្បីគិតថា **ខ្ញុំធ្វើដូចម្តេចដើម្បីបម្រើព្រះសហាគមន៍? ខ្ញុំធ្វើដូចម្តេចដើម្បីបម្រើបងប្អូនឯទៀត? ខ្ញុំធ្វើដូចម្តេចដើម្បីបម្រើនិងស្រឡាញ់ព្រះជាម្ចាស់ថែមទៀត?**។ សូមបងប្អូនអធិដ្ឋានពិសេសសម្រាប់លោកឪពុកវីរៈឆ័យ ដើម្បីឲ្យលោកចាប់មានសុខភាពល្អប្រសើរវិញ ហើយយើងមានលោកឪពុក ដុស្ស និងលោកឪពុក នីកុន នឹងត្រូវបម្រើព្រះសហាគមន៍មណ្ឌលសកម្មភាពទន្លេមេគង្គបន្តទៀត រួមជាមួយបងស្រីបួននាក់ផងដែរ។ ព្រះសហាគមន៍របស់យើងសព្វថ្ងៃនៅប្រទេសកម្ពុជា មានបូជាចារ្យតិចណាស់ ហើយម្យ៉ាងមានបូជាចារ្យមួយចំនួនត្រូវទៅបំពេញបេសកកម្មនៅប្រទេសផ្សេង ដូច្នេះយុវជនទាំងអស់ត្រូវគិតអំពីជីវិតជាបូជាចារ្យនៅថ្ងៃអនាគត ដើម្បីបន្តបម្រើព្រះសហាគមន៍និងបម្រើបងប្អូន សំខាន់ឲ្យបងប្អូនយកចិត្តទុកដាក់បម្រើ អប់រំ ស្រឡាញ់ព្រះសហាគមន៍ជានិច្ច ដើម្បីអនុវត្តព្រះបន្ទូលជាក់ស្តែង "ខ្ញុំបង្គាប់បងប្អូនឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់បងប្អូន ហើយដើរតាមមាគ៌ារបស់ព្រះអង្គ"។ យប់នេះយើងអធិដ្ឋានសម្រាប់ព្រះសហាគមន៍យើង យើងអធិដ្ឋានសម្រាប់បងប្អូនទាំងអស់ ឲ្យយើងទៅជាគ្រីស្តបរិស័ទគំរូតាមព្រះយេស៊ូ ដែលជាព្រះដ៏វិសុទ្ធ។ អាម៉ែន។